មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

## វិចារណកថាព័ត៌មានរបស់ ម.ស.ម.ក

**ភ្នំពេញ ថ្ងៃទី៤ ខែមករា ឆ្នាំ២០១២**

# ការបណ្តេញប្រជាពលរដ្ឋក្នុងតំបន់បុរីកីឡាកាលពីម្សិលមិញ គឺជាការខកខានមិនបានគោរពតាម "មូលដ្ឋានសសរស្តម្ភបី" របស់គោលការណ៍សិទ្ធិមនុស្ស និងអាជីវកម្ម

សារព័ត៌មាន ឌឹ ភ្នំពេញប៉ុស្ត៍ នាថ្ងៃនេះបានរាយការណ៍ក្នុងអត្ថបទមួយមានចំណងជើង ("ហិង្សាក្នុងការបណ្តេញអ្នកបុរីកីឡា") ថាប្រជាពលរដ្ឋក្នុងសហគមន៍បុរីកីឡានៅទីក្រុងភ្នំពេញ រងការបណ្តេញចេញពីផ្ទះកាលពីម្សិលមិញ មុនពេលដែលផ្ទះទាំងនោះត្រូវបានកម្ទេច។ មានមនុស្សយ៉ាងតិច១០នាក់ ត្រូវបានរាយការណ៍ថារងរបួស និងមនុស្សចំនួន១០នាក់ទៀតត្រូវបានឃាត់ខ្លួនក្នុងការប៉ះទង្គិចគ្នាដោយហិង្សាមួយរវាងប្រជាពលរដ្ឋ និងកងកម្លាំងចម្រុះ រួមមាននគរបាលខណ្ឌ ក្រុមទាហាន និងក្រុមសន្តិសុខដែលមកពីក្រុមហ៊ុនផាន អ៊ី-មិច។ ក្នុងឆ្នាំ២០០៣ ក្រុមហ៊ុនផាន អ៊ីមិចបានចុះកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ថានឹងសាងសង់អាគារចំនួន១០ខ្នង នៅលើដីពីរហិកតាសម្រាប់ប្រជាពលរដ្ឋប្រមាណ ១.៧៧៦គ្រួសារ ដើម្បីជាថ្នូរនឹងសិទ្ធិអភិវឌ្ឍលើដីដែលនៅសល់ចំនួន ២,៦ហិកតា។ ក្រុមហ៊ុននេះត្រូវបានគេនិយាយថាបានសង់អាគារតែ៨ខ្នងប៉ុណ្ណោះ បណ្តាលឲ្យប្រជាពលរដ្ឋចំនួន ៤០០គ្រួសារ គ្មានផ្ទះសំបែងស្នាក់នៅ ហើយដែលបានបំពានលើកិច្ចសន្យាកាលពីឆ្នាំ២០០៣។ កាលពីម្សិលមិញ ក្តីសង្ឃឹមរបស់ក្រុមគ្រួសារទាំងនេះកាន់តែអាប់អួរទៅ ដោយសារផ្ទះរបស់ពួកគាត់ត្រូវបានកម្ទេចចោលអស់។

ក្នុងឆ្នាំ២០០៨ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានរួមគ្នាជាឯកច្ឆន្ទដើម្បីស្វាគមន៍ក្របខណ្ឌគោលការណ៍ "ការការពារ ការគោរព និងដំណោះស្រាយ" ដែលស្នើឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងដែន និងសហគ្រាស គឺលោកសាស្ត្រាចារ្យ ចន រូហ្គី។ ក្របខណ្ឌមួយនេះរួមមានសសរស្តម្ភចំនួនបីគឺ ៖ (១) រដ្ឋមានតួនាទីការ-ពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សដោយភាគីទីបី រាប់បញ្ចូលទាំងសហគ្រាសពាណិជ្ជកម្មផងដែរ (២) ការទទួលខុសត្រូវរបស់សាជីវកម្មក្នុងការគោរពសិទ្ធិមនុស្ស និង (៣) សេចក្តីត្រូវការឲ្យបានទទួលការដោះស្រាយកាន់តែទូលំទូលាយឡើង សម្រាប់ជនរងគ្រោះនៃអំពើរំលោភបំពានពាក់ព័ន្ធនឹងអាជីវកម្ម ទាំងតាមប្រព័ន្ធយុត្តិធម៌ និងក្រៅប្រព័ន្ធយុត្តិធម៌។ សម្រាប់ព័ត៌មានបន្ថែម សូមអានរបាយការណ៍ ម.ស.ម.ក ឆ្នាំ២០១០ "អាជីវកម្ម និងសិទ្ធិមនុស្សនៅកម្ពុជា ៖ ការកសាងសសរស្តម្ភបី" ។

ការបណ្តេញចេញនៅបុរីកីឡា គឺជាការរំលោភបំពានដ៏ជាក់ស្តែងមកលើសសរស្តម្ភទាំងបី ៖ រដ្ឋគួរមិនត្រឹមតែខកខានមិនបានបំពេញតាមកាតព្វកិច្ចរបស់ខ្លួនដើម្បីការពារប្រជាពលរដ្ឋពីការរំលោភបំពានរបស់ក្រុមហ៊ុន ផាន អ៊ីមិច នោះទេ ប៉ុន្តែថែមទាំងបានជួយដល់ក្រុមហ៊ុននេះយ៉ាងសកម្ម ដោយបានផ្តល់នូវកងកម្លាំងនគរបាល ដើម្បីជាជំនួយដល់ការបណ្តេញចេញ និងកម្ទេចផ្ទះ ហើយក្រុមហ៊ុន ផាន អ៊ីមិច ផ្ទាល់ក៏ខកខានមិនបានគោរពសិទ្ធិរបស់ប្រជាពលរដ្ឋដែលក្រុមហ៊ុននេះបានសន្យាថានឹងជួយកាលពីមុនទៀតផង ដោយបានកម្ទេចផ្ទះពួកគាត់តាមទំនើងចិត្ត គឺបានបំពានដល់ដំណើរការចរចាដែលកំពុងបន្ត ហើយដូច្នេះរាល់ការទទួលបានការដោះស្រាយទាំងឡាយត្រូវបានបដិសេធ។

អាជីវកម្មដែលទទួលបានជោគជ័យ និងរីកចម្រើនបំផុត ជុំវិញពិភពលោកគឺសុទ្ធតែមានទំនោរទទួលស្គាល់ "ករណីអាជីវកម្ម" ដែលសង្កេតមើលសិទ្ធិមនុស្ស ទទួលបានការគោរពពីសហគមន៍ដែលក្រុមហ៊ុនទាំងនោះកំពុងធ្វើប្រតិបត្តិការ និងរក្សាកេរ្តិ៍ឈ្មោះបានយ៉ាងល្អប្រពៃ។ សកម្មភាពដូចជាការបណ្តេញចេញនៅបុរីកីឡា មិនត្រឹមតែប៉ះពាល់ដល់សហគមន៍ក្នុងមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែក៏ប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនដែលពាក់ព័ន្ធ ហើយអ្វីដែលធ្ងន់ធ្ងរជាងនេះ និងមិនអាចចៀសវាងបានគឺកិត្តិយសរបស់ប្រទេសកម្ពុជាទាំងមូល។

**ចំពោះការបណ្តេញចេញនៅបុរីកីឡា លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានមានប្រសាសន៍ថា ៖**

*"ការបណ្តេញចេញនេះ គ្រាន់តែជាឧទាហរណ៍មួយទៀតនៃភាពចលាចលក្នុងអាជីវកម្មដែលកំពុងតែរីករាលដាលនៅកម្ពុជា។ ព្រឹត្តិការណ៍កាលពីម្សិលមិញ បានបង្ហាញយ៉ាងច្បាស់ថា នេះមិនមែនជាមជ្ឈដ្ឋានអាជីវកម្មដ៏ល្អប្រសើរនោះទេ ហើយថែមទាំងបន្លាចដល់ការវិនិយោគទុនបរទេសដែលចាំបាច់ដទៃទៀតផង។ ប្រទេសកម្ពុជាគួរតែខិតខំពង្រឹងជំហររបស់ខ្លួនឲ្យប្រៀបដូចជាទីផ្សារសក្តានុពលដ៏រីកចម្រើននាំមុខគេមួយ ជាជាងអនុញ្ញាតឲ្យវប្បធម៌បែបព្រៃនេះបន្តកើតមាន គឺជាវប្បធម៌ដែលក្រុមហ៊ុនខៅប៊ិយជិះសេះជាន់លើជីវិតមនុស្ស និងផ្ទះសំបែង។ ការផ្លាស់ប្តូរគឺពិតជាត្រូវការជាចាំបាច់ ហើយការពិនិត្យមើលលើសសរស្តម្ភបីរបស់ អង្គការសហប្រជាជាតិគឺជាការចាប់ផ្តើមដ៏ប្រសើរមួយ។ លទ្ធផលទាំងនេះនឹងបង្កើននូវទំនុកចិត្ត និងការវិនិយោគបរទេស ដែលការអភិវឌ្ឍន៍ទាំងនោះនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប" ។*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖ លោក អ៊ូ វីរៈ ទូរស័ព្ទលេខ +៨៥៥ ១២ ៤០ ៤០ ៥១ អ៊ីម៉ែល ៖** ouvirak@cchrcambodia.org ។